ព្រះយេស៊ូវមកសុគត់លើឈើឆ្កាងសំរាប់ចេញថ្លៃលោះ អំពើបាបអ្នករឺទេ ? ទ្រង់បានសុគត់បញ្ចុះក្នុងផ្នូរ ហេយទ្រង់រស់ឡើងវិញសំរាប់ទទួលរងនូវអំពើទុច្ចរិតរបស់អ្នក ។ តើអ្នកហ៊ាននិយាយ ដោយចំហរដែររឺទេ ? បើសិនជាអ្នកចង់
បន្ទាប់មកព្រះនឹងប្រកាសថាអ្នកនិងបានសង្គ្រោះ ។

មានមនុស្សជាច្រើនគេគិតថា ព្រលឹងរបស់ពួកគេមិនសំខាន់ទេ ។ ប៉ុន្តែ មិនមែនជាការពិតទេ ។ ព្រះជាម្ចាស់បានបង្កើតអ្នករាល់គ្នាមកសំខាន់ជាងអ្វីៗនៅលើផែនដីនេះ ហើយទ្រង់បានបង្ហាញភស្តុតាងដល់យើងគឺថា ទ្រង់បានបញ្ជូនបុត្រាទ្រង់មកសុគតជំនួសយើង ។ ប្រសិនបើ អ្នកសំរេចចិត្តទទួលយកព្រះយេស៊ូវគ្រីស្ទជាព្រះអង្គសង្គ្រោះរបស់អ្នកហេតុអ្វីមិនយកពេលវេលានេះ អរព្រះគុណដល់ទ្រង់សំរាប់ក្ដីកង្វល់របស់អ្នក ហើយយាងទ្រង់ឱ្យគង់ក្នុងចិត្តអ្នក ។

ចូរឱ្យការអធិដ្ឋានរបស់អ្នកចេញពីចិត្តស្មោះត្រង់ និងពីចិត្តខ្ទេចខ្ទាំរបស់អ្នក ។ បើខិត្តប័ណ្ណនេះ ជួយអោយអ្នកស្គាល់ព្រះយេស៊ូវគ្រីស្ទសូមបំពេញឈ្មោះនិងអាស័យដ្ឋានអ្នកឱ្យយើងខ្ញុំបានដឹង យើងនឹងទទួលអ្នកដោយរីករាយ ។

Hope tract ministry
All tracts are free, as the Lord provides

P.O. BOX 609 • YORK, SC 29745 • 803-684-1535
WWW.HOPETRACTS.ORG
What Is The Most Important Thing? (Khmer) Tract 385

# តើមានអ្វីដែលមានសារៈសំខាន់បំផុតនៅក្នុងលោកីយ៍នេះ ?



អ្នកធ្លាប់គិតពិចារណាដែរទេថា : តើការអ្វីដែលព្រះជាម្ចាស់គិតថាដែលសំខាន់បំផុតក្នុងលោកីយ៏នេះ ? តើជាមាស ជាប្រាក់ ភាពមានស្តុកស្តម្ភនៃមនុស្សជាតិ ទីកន្លែងដ៏ស្រស់ស្អាត ជាមនុស្សល្បីល្បាញ រឺក៏ ចងមានអ្នកហែហមទៅរឺ ?

តើអាចជាគំនិតរបស់អ្នកវិទ្យាសាស្ត្រ  អ្នកថ្លែងសន្ទរកថា ត្រូវតែជាអ្នកនិយាយបានល្អ រឺ ការសិក្សានៅវិទ្យាស្ថានត្រូវការបន្ទប់ដ៏ធំៗទៅរឺ ? ពិតមែនហើយ មិនអាចមានការទាំងអស់នេះដូចការរៀបរាប់ខាងលើនេះបានទេ ។

នេះជាការពិត (យ៉ូហាន៣:១៦= ដ្បិតព្រះទ្រង់ស្រលាញ់មនុស្សលោកដ៏ម៉្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីអោយអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺអោយមានជីវិតអស់កល្បជានិច្ចវិញ ) ។

ហើយពិតណាស់ (លូកា១៩:១០=ដ្បិតកូនមនុស្សបានមកដើម្បីនឹងរក ហើយជួយសង្គ្រោះដល់មនុស្សបាត់បង់ ) ។

ហើយដែលថាៈ (រ៉ូម៣:២៣ =ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ ) ។ ព្រះអម្ចាស់ក៏មានបន្ទូលដែរថា : (ដ្បិតឯ ព្រះអង្គដែលមិនបានស្គាល់បាបសោះ នោះព្រះទ្រង់បានធ្វើអោយត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះដោយនូវព្រះអង្គនោះឯង ) ។(២កូរិនថូស៥:២១ ) ដោយហេតុនេះហើយចិត្តដ៏ស្មោះត្រង់នៃមនុស្សជាតិ គឺសំខាន់បំផុតនៅចំពោះព្រះ ។ ដូច្នេះ ហើយព្រះជាម្ចាស់ចង់អោយសេចក្តីពិតនៃព្រះយេស៊ូវគ្រីស្ទបានទៅដល់មនុស្សទាំងអស់ គឺទាំងបុរស ស្ត្រី ក្មេងប្រុស ក្មេងស្រីនៅលើលោកីយ៏នេះ ។

អត្ថបទដែលនៅក្នុងដៃរបស់អ្នកនេះ ជាចំនែកតូចមួយដែលបញ្ជាក់ពីឋានៈរបស់ព្រះ  ។ អ្នករាល់គ្នានិងយល់ច្បាស់ពីព្រលឹងរបស់ខ្លួន ពេលអានអត្ថបទនេះ ។

បងប្អូនស្ងួនភ្ងា (ព្រះជាម្ចាស់មិនផ្អាកសេចក្តីសន្យារបស់ទ្រង់ ដូចជាមានអ្នកខ្លះគិតស្មាននោះទេ គឺទ្រង់មានព្រះហប្ញទ័យអត់ធ្មត់និងយើងរាល់គ្នាវិញ ដោយមិនចង់ឱ្យអ្នកណាម្នាក់មួយវិនាសឡើយ គឺចង់ឱ្យមនុស្សទាំងអស់បានប្រែចិត្តវិញ) (២ពេត្រុស៣:៩ ) ។

ដូច្នេះ អ្នករាល់គ្នាគឺសំខាន់ណាស់ ។ ហើយមានតែព្រះអម្ចាស់ទេដែលស្គាល់ភាពអស្ចារ្យនៃនគរស្ថានសួគ៌ ហើយនឹងស្ថាននរក  ។ មានតែព្រះអង្គទេដែលអាចសង្គ្រោះអ្នករាល់គ្នាឱ្យរួចពីស្ថាននរកបាន និងស្រង់យកអ្នករាល់គ្នាទៅឯនគរស្ថានសួគ៌ ។ យ៉ាងនេះមិនត្រូវអនុញ្ញាតិឱ្យអ្នកម្នាក់និយាយថា ជីវិតរបស់អ្នកគ្មានតំលៃនោះទេ ព្រោះព្រះអម្ចាស់មានបន្ទូលថា ជីវិតអ្នកមានណាស់  ដែលមិនអាចថ្លៃងបាន ។(ដ្បិតបើមនុស្សណាមិនបានលោកីយ៏ទាំងមូល តែបាត់ព្រលឹងទៅនោះតើមានប្រយោជន៏អ្វីដល់អ្នកនោះ  ? រឺតើមនុស្សនឹងយកអ្វីទៅដូរឱ្យបានព្រលឹងខ្លួនវិញ  ? ) (ម៉ាកុស៨:៣៦-៣៧)  ។

អ្នកគឺជាមនុស្សសំខាន់បំផុតនៅចំពោះព្រះ  ហើយទ្រង់នឹងឱ្យអ្វីៗដែលទ្រង់នឹងប្រទានឱ្យ  ។ ដូចនេះ អ្នកនឹងមានឯកសិទ្ធិនៅឯនគរស្ថានសួគ៌អស់កល្បជានិច្ច  ។

ព្រះយេស៊ូវទ្រង់មានបន្ទូលនៅក្នុងយ៉ូហាន១:១២ (ប៉ុន្តែ អស់អ្នកណាដែលទទួលទ្រង់គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់  នោះទ្រង់បានប្រទានអំណាចអោយបានត្រឡប់ជាកូនព្រះ  )  តើអ្នកសំរេចចិត្តទទួលទ្រង់ដែររឺទេ  ? ទ្រង់ក៏បានមានបន្ទូលក្នុងម៉ាថាយ១១:២៨  ដែលថា :(អស់អ្នកដែលនឿយព្រួយហើយផ្ទុកធ្ងន់អើយ  ចូរមកឯខ្ញុំ  ខ្ញុំនឹងអោយអ្នករាល់គ្នាឈប់សំរាក  ។
តើអ្នកនិងទៅឯទ្រង់រឺទេ  ?ក្នុងព្រះគម្ពីររ៉ូម១០:៩-១០-១៣ បានប្រាប់យើងថា (បើមាត់អ្នកនិងទទួលថ្លែងប្រាប់ពីព្រះអម្ចាស់យេស៊ូវ  ហើយអ្នកជឿក្នុងចិត្តថាព្រះបានប្រោសឱ្យទ្រង់រស់ពីស្លាប់ឡើងវិញ អ្នកនោះនឹងបានសង្គ្រោះ  ។ ដ្បិតយើងបានសុចរិតដោយមានចិត្តជឿហើយក៏បានង្គ្រោះដោយមាត់ទទួលថ្លែងប្រាប់  ។  អស់អ្នកណាដែលជឿដល់ទ្រង់នោះនឹងបានសេចក្តីសង្គ្រោះ  )  ។ តើអ្នកជឿថាព្រះជាម្ចាស់បានបញ្ជូន